**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខៈ.....០០២/១៨....គ.ម.ក/ប្រ.ក.

# ប្រកាស
## ស្តីពី
## ការទទួលស្គាល់ភ្នាក់ងារសន្តិសុខព័ត៌មានក្នុងវិស័យមូលបត្រ

* * * * *

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នា១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០១៨

## ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-គោលបំណង**

ប្រកាសនេះមានគោលបំណងធានានូវការអនុវត្តរបស់ភ្នាក់ងាររក្សាសុវត្ថិភាព តាមរយៈការបង្កើតឱ្យមាននូវយន្តការប្រតិបត្តិការ និងការការពារផលប្រយោជន៍របស់វិនិយោគិន ការរៀបចំឱ្យមានរចនាសម្ព័ន្ធច្បាស់លាស់ក្នុងការទទួលខុសត្រូវដើម្បីធានាឱ្យការផ្តល់សេវារបស់ភ្នាក់ងាររក្សាសុវត្ថិភាពទទួលបានប្រសិទ្ធភាពខ្ពស់។

**ប្រការ ២.-គោលដៅ**

ប្រកាសនេះមានគោលដៅកំណត់នូវលក្ខខណ្ឌតម្រូវ យន្តការ នីតិវិធីដើម្បីផ្តល់ការទទួលស្គាល់ធ្វើជាភ្នាក់ងាររក្សាសុវត្ថិភាពព្រមទាំងកំណត់អំពីកាតព្វកិច្ចរបស់ភ្នាក់ងារដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ៣.-វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះភ្នាក់ងាររក្សាសុវត្ថិភាព ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ឱ្យធ្វើប្រតិបត្តិការផ្តល់សេវារក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.-និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន÷

-គណនីរក្សាសុវត្ថិភាព **(Custody Account)** សំដៅដល់គណនីអតិថិជនដែលបើក និងត្រូវបានរក្សាដោយភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ។

-បុគ្គលដាក់ពាក្យស្នើសុំ សំដៅដល់បុគ្គលដែលដាក់ពាក្យស្នើសុំការទទួលស្គាល់ធ្វើជាភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ។

-ភ្នាក់ងារ **(Agent)** សំដៅដល់ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រដែលទទួលបានការទទួលស្គាល់ពីអគ្គនាយកនៃ **គ.ម.ក.** ដើម្បីផ្តល់សេវារក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ។

-សេវា សំដៅដល់សេវាដែលបានផ្តល់ជូនដោយភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ។

-អតិថិជន សំដៅដល់បុគ្គលដែលបើកគណនី និងបានចុះកិច្ចព្រមព្រៀងជាមួយភ្នាក់ងាររក្សាសុវត្ថិភាព។

## ជំពូកទី ២
## លក្ខខណ្ឌតម្រូវដើម្បីទទួលបានការទទួលស្គាល់ជាភ្នាក់ងារ

### ប្រការ ៥.-បុគ្គលដែលអាចធ្វើជាភ្នាក់ងារ

បុគ្គលដែលអាចទទួលបានការទទួលស្គាល់ធ្វើជាភ្នាក់ងារត្រូវជា ÷

-ធនាគារពាណិជ្ជ ដែលបង្កើតឡើងស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងបទប្បញ្ញត្តិពាក់ព័ន្ធវិស័យធនាគារ និងត្រូវទទួលបានជាមុននូវលិខិត "មិនជំទាស់" ពីធនាគារជាតិនៃកម្ពុជា ។

-ប្រតិបត្តិកររក្សាទុកមូលបត្រ នៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

### ប្រការ ៦.-លក្ខខណ្ឌតម្រូវ

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារត្រូវ÷

១-មានមូលធនអប្បបរមាចំនួន ៤.០០០.០០០.០០០ (បួនបីលាន) រៀល និងដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១៥ (ដប់ប្រាំ) ភាគរយ នៃមូលធនអប្បបរមាក្នុងគណនី **គ.ម.ក.** នៅធនាគារជាតិនៃកម្ពុជា។ បុគ្គលដាក់ពាក្យស្នើសុំដែលជាធនាគារពាណិជ្ជនៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនតម្រូវឱ្យបំពេញលក្ខខណ្ឌមូលធនអប្បបរមានេះទេ ប៉ុន្តែត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល ក្នុងគណនីរបស់ **គ.ម.ក.** នៅធនាគារជាតិនៃកម្ពុជា។

២-មានសមត្ថភាពប្រតិបត្តិការខ្ពស់។

៣-មានផ្នែកដាច់ដោយឡែកសម្រាប់ធ្វើប្រតិបត្តិការជាភ្នាក់ងារដោយត្រូវមានរបាំងព័ត៌មាន (Chinese Wall) សមស្រប។

៤-មានធនធានមនុស្សដែលបំពេញលក្ខខណ្ឌដូចខាងក្រោម÷

-អភិបាល ១ (មួយ) រូប ដែលទទួលបន្ទុកផ្នែកភ្នាក់ងារ ត្រូវបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ។

-ប្រធានប្រតិបត្តិការ ត្រូវបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ៨ នៃប្រកាសនេះ។

-ប្រធានបុគ្គលិកជំនាញផ្នែកច្បាប់ ត្រូវបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ៩ នៃប្រកាសនេះ។

-ប្រធានទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ ត្រូវបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ។

៥-មានប្រព័ន្ធព័ត៌មានវិទ្យា (IT System) រួមមានប្រព័ន្ធទ្រទ្រង់ (Back-up System) ប្រព័ន្ធស្តារទិន្នន័យ (Recovery System) និងប្រព័ន្ធតភ្ជាប់ សម្រាប់ធ្វើប្រតិបត្តិការដើម្បីធានាឱ្យបាននូវភាពជឿជាក់ ប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព និងចីរភាព។

៦-មានទីតាំងសមស្របប្រកបដោយសុវត្ថិភាព ដើម្បីជំនះពីហានិភ័យដែលនាំឱ្យមានការបំផ្លិចបំផ្លាញ ឬការបាត់បង់។

៧-មានគោលការណ៍ស្តីពីសេវារក្សាសុវត្ថិភាព ដូចមានចែងក្នុងប្រការ ២១ នៃប្រកាសនេះ និងត្រូវទទួលបានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.**។

៨- មានគោលនយោបាយ យន្តការ នីតិវិធី សម្រាប់ប្រតិបត្តិការដើម្បីធានាបានប្រសិទ្ធភាពក្នុងការផ្តល់សេវាជូនអតិថិជន។

៩- មានគោលការណ៍ស្គាល់អតិថិជន (Know Your Client)។

១០- មានផែនការធុរកិច្ច (Business Plan) សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ ផែនការគ្រប់គ្រងហានិភ័យ (Risk Management Plan) និងផែនការយថាភាព (Contingency Plan) ព្រមទាំងមានយន្តការត្រួតពិនិត្យផ្ទៃក្នុង (Internal Control)។

## ប្រការ ៧.- លក្ខណសម្បត្តិរបស់អភិបាល

បុគ្គលដែលត្រូវតែងតាំងជាអភិបាលទទួលបន្ទុករបស់បុគ្គលដាក់ពាក្យស្នើសុំ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម÷

១- ត្រូវមានសញ្ញាបត្រយ៉ាងតិចចាប់ពីកម្រិតឧត្តមសិក្សាពាក់ព័ន្ធជំនាញគ្រប់គ្រង សេដ្ឋកិច្ច ឬ ហិរញ្ញវត្ថុ។

២- ត្រូវមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងវិស័យមូលបត្រ ឬវិស័យហិរញ្ញវត្ថុ ។

៣- មានលក្ខណសម្បត្តិ និងអត្តចរិតល្អដូចមានចែងក្នុងមាត្រា ៤២ នៃអនុក្រឹត្យ។

៤- មិនធ្លាប់ត្រូវបានប្រកាសក្ស័យធន ឬមិនធ្លាប់បង្កឱ្យក្រុមហ៊ុនមួយ ឬច្រើនដែលធ្លាប់បម្រើការងារឈានទៅរកភាពក្ស័យធនក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយគិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ។

៥- មិនធ្លាប់ប្រព្រឹត្តអំពើអ្វីដែលនាំឱ្យប៉ះពាល់ដល់ដំណើរការទីផ្សារមូលបត្រ ឬក្នុងវិស័យហិរញ្ញវត្ថុ។

៦- មិនធ្លាប់ប្រព្រឹត្តអ្វីដែលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈធ្ងន់ធ្ងរ។

## ប្រការ ៨.- ប្រធានប្រតិបត្តិការ

បុគ្គលដែលត្រូវតែងតាំងជាប្រធានប្រតិបត្តិការរបស់បុគ្គលដាក់ពាក្យស្នើសុំ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម÷

១- ត្រូវមានសញ្ញាបត្រយ៉ាងតិចចាប់ពីកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងជំនាញគ្រប់គ្រង សេដ្ឋកិច្ច ឬហិរញ្ញវត្ថុ។

២- ត្រូវមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងវិស័យមូលបត្រ ឬវិស័យហិរញ្ញវត្ថុ។

## ប្រការ ៩.- ប្រធានបុគ្គលិកជំនាញផ្នែកច្បាប់

បុគ្គលដែលត្រូវតែងតាំងជាប្រធានបុគ្គលិកជំនាញផ្នែកច្បាប់របស់បុគ្គលដាក់ពាក្យស្នើសុំ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម÷

១- ត្រូវមានសញ្ញាបត្រយ៉ាងតិចចាប់ពីកម្រិតឧត្តមសិក្សាផ្នែកច្បាប់ ។

២- ត្រូវមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងវិស័យមូលបត្រ ឬវិស័យហិរញ្ញវត្ថុ ។

## ប្រការ ១០.- ប្រធានទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ

បុគ្គលដែលត្រូវតែងតាំងជាប្រធានទទួលបន្ទុកផ្នែកហិរញ្ញវត្ថុរបស់បុគ្គលដាក់ពាក្យស្នើសុំ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម÷

១- ត្រូវមានសញ្ញាបត្រយ៉ាងតិចចាប់ពីកម្រិតឧត្តមសិក្សាពាក់ព័ន្ធជំនាញផ្នែកហិរញ្ញវត្ថុ ឬគណនេយ្យ។

២- ត្រូវមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងវិស័យមូលបត្រ ឬវិស័យហិរញ្ញវត្ថុ ។

## ជំពូកទី ៣
## នីតិវិធីដើម្បីទទួលបានការទទួលស្គាល់ជាភ្នាក់ងារ

**ប្រការ ១១.-ការដាក់ពាក្យស្នើសុំ**

បុគ្គលដែលមានបំណងធ្វើជាភ្នាក់ងារត្រូវដាក់ពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១២.-ឯកសារភ្ជាប់**

បុគ្គលដាក់ពាក្យស្នើសុំត្រូវភ្ជាប់មកជាមួយនូវពាក្យស្នើសុំ និងឯកសារភ្ជាប់ដូចខាងក្រោម÷

១-អាជ្ញាបណ្ណធនាគារពាណិជ្ជ ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

២-វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

៣-បណ្ណពន្ធប៉ាតង់ (ឆ្នាំចរន្ត) ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

៤-វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

៥-លក្ខន្តិកៈក្រុមហ៊ុន ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

៦-លិខិតបញ្ជាក់ពីដើមទុនអប្បបរមា (ករណីមិនមែនជាធនាគារពាណិជ្ជ)។

៧-លិខិតបញ្ជាក់ពីការដាក់ប្រាក់តម្កល់ធានាអាជីវកម្ម។

៨-អង្គការលេខស្តីពីរចនាសម្ព័ន្ធរបស់ធនាគារពាណិជ្ជ ឬប្រតិបត្តិកររក្សាទុកមូលបត្រនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងផ្នែកសេវារក្សាសុវត្ថិភាពរបស់បុគ្គលដាក់ពាក្យស្នើសុំ។

៩-ប្រវត្តិរូបសង្ខេប សញ្ញាបត្រ លិខិតបញ្ជាក់ពីបទពិសោធន៍ការងារ លិខិតថ្កោលទោសដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន ដោយមានចុះហត្ថលេខា ឬស្នាមម្រាមដៃរបស់អភិបាលទទួលបន្ទុក ប្រធានប្រតិបត្តិការ ប្រធានបុគ្គលិកជំនាញផ្នែកច្បាប់ និងប្រធានទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

១០-របាយការណ៍ហិរញ្ញវត្ថុ ឬរបាយការណ៍ហិរញ្ញវត្ថុរួម ដែលធ្វើសវនកម្មរួចដោយសវនករឯករាជ្យសម្រាប់រយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ។

១១-គំរូកិច្ចព្រមព្រៀងអតិថិជន។

១២-គោលការណ៍ស្តីពីសេវារក្សាសុវត្ថិភាព ដោយអនុលោមតាមប្រការ ២១ នៃប្រកាសនេះ និងយន្តការផ្តល់សេវារបស់បុគ្គលដាក់ពាក្យស្នើសុំ។

១៣-គោលនយោបាយ នីតិវិធី យន្តការ សម្រាប់ប្រតិបត្តិការ។

១៤-ឯកសារពាក់ព័ន្ធនឹងប្រព័ន្ធព័ត៌មានវិទ្យាដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ។

១៥-ផែនការធុរកិច្ច ផែនការគ្រប់គ្រងហានិភ័យ និងផែនការយថាភាព ។

**ប្រការ ១៣.- ឯកសារ និងការបំភ្លឺបន្ថែម**

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំផ្តល់ឯកសារ និងបំភ្លឺនូវចំណុច ឬព័ត៌មានផ្សេងទៀត តាមការចាំបាច់ដើម្បីធានាថាបុគ្គលដាក់ពាក្យស្នើសុំបំពេញបានគ្រប់លក្ខខណ្ឌដែលមានចែងក្នុងប្រកាសនេះ ។

**ប្រការ ១៤.-ការផ្ដល់ការទទួលស្គាល់**

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបុគ្គលដាក់ពាក្យស្នើសុំអំពីការទទួលស្គាល់ ឬការបដិសេធពាក្យស្នើសុំក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ បន្ទាប់ពីទទួលបានឯកសារពេញលេញ។

**ប្រការ ១៥.-ការបដិសេធពាក្យស្នើសុំ**

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើពាក្យស្នើសុំធ្វើជាភ្នាក់ងារ ដោយផ្អែកលើមូលហេតុ ដូចខាងក្រោម÷

១-បុគ្គលដាក់ពាក្យស្នើសុំមិនបានបំពេញនូវលក្ខខណ្ឌណាមួយដែលមានចែងក្នុងប្រកាសនេះ ឬ សេចក្ដីណែនាំផ្សេងទៀតដែលអនុលោមតាមប្រកាសនេះ ឬបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធផ្សេងទៀត។

២-ព័ត៌មាន ឬឯកសារដែលបុគ្គលដាក់ពាក្យស្នើសុំបានដាក់ជូន **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស។

៣-បុគ្គលដាក់ពាក្យស្នើសុំស្ថិតក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ ឬរំលាយអាជីវកម្ម។

៤-បុគ្គលដាក់ពាក្យស្នើសុំមិនបានទូទាត់សងបំណុលមួយផ្នែក ឬទាំងស្រុងតាមសេចក្ដីសម្រេចរបស់តុលាការ។

៥-បុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាលទទួលបន្ទុក ឬប្រធានប្រតិបត្តិការ ឬប្រធានបុគ្គលិកជំនាញផ្នែកច្បាប់ ឬប្រធានទទួលបន្ទុកផ្នែកហិរញ្ញវត្ថុរបស់បុគ្គលដាក់ពាក្យស្នើសុំ÷

ក-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ខ-បានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិដែលការពារសាធារណជនឱ្យជៀសផុតពីការខាតបង់ផ្នែកហិរញ្ញវត្ថុដោយសារតែភាពមិនស្មោះត្រង់ ឬអសមត្ថភាព ឬការប្រព្រឹត្តមិនត្រឹមត្រូវរបស់បុគ្គលនោះក្នុងការផ្ដល់សេវាហិរញ្ញវត្ថុ ឬក្នុងការគ្រប់គ្រងក្រុមហ៊ុន។

គ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាផ្សេងទៀត ដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្ដីសម្រេចរបស់ខ្លួន ឬមានទំនាស់ផលប្រយោជន៍។

ឃ-ស្ដែងចេញនូវភាពមិនអាចធ្វើសកម្មភាពដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួនដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្ដីសុចរិត និងភាពដែលអាចទុកចិត្តបានផ្នែកហិរញ្ញវត្ថុរបស់បុគ្គលទាំងនោះ។

ង-ស្ដែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌនៃការទទួលស្គាល់ប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ និងយុត្តិធម៌។

៦-បុគ្គលដាក់ពាក្យស្នើសុំ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៥ (ប្រាំ)ឆ្នាំ ចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៧-នៅពេលកើតមានហេតុការណ៍ណាមួយដែលអាច÷

ក-នាំឱ្យបុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាលទទួលបន្ទុក ឬប្រធានប្រតិបត្តិការ ឬប្រធានបុគ្គលិកជំនាញផ្នែកច្បាប់ ឬប្រធានទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំមិនអាចធ្វើអាជីវកម្មបានត្រឹមត្រូវ។

ខ-ឆ្លុះបញ្ចាំងពីភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ។

៨- បុគ្គលដាក់ពាក្យស្នើសុំមាន ឬអាចនឹងមានការពាក់ព័ន្ធនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬការទទួលស្គាល់បុគ្គលដាក់ពាក្យស្នើសុំអាចនឹងនាំឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈ។

អគ្គនាយកនៃ **គ.ម.គ.** មិនត្រូវបដិសេធលើពាក្យស្នើសុំការទទួលស្គាល់ធ្វើជាភ្នាក់ងារដោយមិនបានផ្តល់ឱកាសឱ្យបុគ្គលដាក់ពាក្យស្នើសុំធ្វើការពន្យល់ឡើយ។

### ប្រការ ១៦.-សុពលភាពនៃការទទួលស្គាល់

សុពលភាពនៃការទទួលស្គាល់មានរយៈពេលមិនកំណត់។

## ជំពូកទី ៤
## ថ្លៃសេវានៃការទទួលស្គាល់

### ប្រការ ១៧.-ថ្លៃសេវាសិក្សាសំណុំលិខិត

បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ២.០០០.០០០ (ពីរលាន) រៀល នៅពេលដាក់ពាក្យស្នើសុំ។

### ប្រការ ១៨.-ការមិនសងត្រឡប់

សំណុំឯកសារនៃពាក្យស្នើសុំ ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត មិនត្រូវបានប្រគល់ជូនបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីជាមានការបដិសេធលើពាក្យស្នើសុំក៏ដោយ។

### ប្រការ ១៩.-ថ្លៃសេវានៃការទទួលស្គាល់ប្រចាំឆ្នាំ

ភ្នាក់ងារត្រូវបង់ថ្លៃសេវានៃការទទួលស្គាល់ប្រចាំឆ្នាំចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ឱ្យបានមុនថ្ងៃទី ១៥ ខែមករា ជារៀងរាល់ឆ្នាំ។ សម្រាប់ថ្លៃសេវាឆ្នាំដំបូង ថ្លៃសេវាទទួលស្គាល់ត្រូវបង់ ដូចខាងក្រោម÷

- ករណីទទួលបានការទទួលស្គាល់ក្នុងត្រីមាសទី១÷ ត្រូវបង់ថ្លៃការទទួលស្គាល់ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល។
- ករណីទទួលបានការទទួលស្គាល់ក្នុងត្រីមាសទី២÷ ត្រូវបង់ថ្លៃការទទួលស្គាល់ចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល។
- ករណីទទួលបានការទទួលស្គាល់ក្នុងត្រីមាសទី៣÷ ត្រូវបង់ថ្លៃការទទួលស្គាល់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល។
- ករណីទទួលបានការទទួលស្គាល់ក្នុងត្រីមាសទី៤÷ ត្រូវបង់ថ្លៃការទទួលស្គាល់ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល។

### ប្រការ ២០.-ថ្លៃសេវាផ្សេងៗ

ភ្នាក់ងារត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត ចំនួន ១០០.០០០ (មួយសែន) រៀល នៅពេលដាក់ពាក្យស្នើសុំតែងតាំង ឬផ្លាស់ប្តូរអភិបាលទទួលបន្ទុក ប្រធានប្រតិបត្តិការ ប្រធានបុគ្គលិកជំនាញផ្នែកច្បាប់ ឬប្រធានទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ និងផ្លាស់ប្តូរទីតាំងប្រកបអាជីវកម្ម ឬកែប្រែគោលការណ៍ស្តីពីសេវាសេវារក្សាសុវត្ថិភាព ឬកែប្រែគំរូកិច្ចព្រមព្រៀងអតិថិជន។

## ជំពូកទី ៥
## គោលការណ៍ស្ដីពីសេវារក្សាសុវត្ថិភាព និងកិច្ចព្រមព្រៀងអតិថិជន

### ប្រការ ២១.-គោលការណ៍ស្ដីពីសេវារក្សាសុវត្ថិភាព

គោលការណ៍ស្ដីពីសេវារក្សាសុវត្ថិភាព របស់បុគ្គលដាក់ពាក្យស្នើសុំត្រូវចែងនូវចំណុចជាអប្បបរមា ដូចតទៅ÷

១-សេវាដែលត្រូវផ្ដល់ឱ្យអតិថិជន។

២-ការអនុវត្តប្រតិបត្តិការរក្សាសុវត្ថិភាពសាច់ប្រាក់ មូលបត្រ និងទ្រព្យដទៃទៀតក្នុងនាមអតិថិជន។

៣-ការទូទាត់សាច់ប្រាក់ មូលបត្រ និងទ្រព្យដទៃទៀតក្នុងនាមអតិថិជន។

៤-ការផ្ដល់សេវាចាត់ចែង និងការតាមដានសាច់ប្រាក់ មូលបត្រ និងទ្រព្យដទៃទៀតក្នុងនាមអតិថិជនសម្រាប់ការវិនិយោគពាក់ព័ន្ធនឹងមូលបត្រ។

៥-វិធីសាស្ត្រនៃការគណនាទ្រព្យសកម្មសុទ្ធ និងការកត់ត្រាទ្រព្យរបស់អតិថិជនតាមតម្លៃទីផ្សារ (Mark-to-Market Valuation) និងនីតិវិធីស្ដីពីការពិនិត្យ និងការរាយការណ៍ទ្រព្យសកម្មសុទ្ធ។

៦-ការរៀបចំការងារពាក់ព័ន្ធនឹងផលប្រយោជន៍ និងសិទ្ធិរបស់កម្មសិទ្ធិករមូលបត្រ (Corporate Actions) រួមទាំងការប្រមូលចំណូលពីការវិនិយោគពាក់ព័ន្ធនឹងមូលបត្រ និងធ្វើសកម្មភាពដើម្បីអត្ថប្រយោជន៍ដទៃទៀតក្នុងនាមអតិថិជន។

៧-ការផ្ដល់ព័ត៌មានដល់អតិថិជន និងភាគីពាក់ព័ន្ធដទៃទៀត នូវសេវានានាដែលបានអនុវត្ត។

៨-ការគ្រប់គ្រងនូវរាល់អាកប្បកិរិយាដែលត្រូវបានហាមឃាត់ទាក់ទិនទៅនឹងវិស័យមូលបត្រដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៩-គោលការណ៍ស្គាល់អតិថិជន ។

១០-ការផ្ដល់សេវាដទៃទៀតដែលទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

ភ្នាក់ងារមិនត្រូវ កែប្រែ ឬលុបចោលគោលការណ៍ស្ដីពីសេវារក្សាសុវត្ថិភាព ដោយគ្មានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.** ឡើយ។

### ប្រការ ២២.-កិច្ចព្រមព្រៀងអតិថិជន

កិច្ចព្រមព្រៀងអតិថិជនត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានហត្ថលេខាត្រឹមត្រូវរវាងអតិថិជន និងភ្នាក់ងារ។ ភ្នាក់ងារត្រូវពន្យល់ពីខ្លឹមសារនីមួយៗនៃកិច្ចព្រមព្រៀង និងត្រូវទទួលបានការឯកភាពពីអតិថិជនមុននឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

កិច្ចព្រមព្រៀងអតិថិជនត្រូវមាននិទ្ទេសអប្បបរមា ដូចខាងក្រោម÷

១-នាមករណ៍ និងអាសយដ្ឋានរបស់ភ្នាក់ងារ។

២-អត្តសញ្ញាណរបស់អតិថិជនដោយភ្ជាប់មកជាមួយនូវលេខអត្តសញ្ញាណវិនិយោគិនដែលទទួលបានពី **គ.ម.ក.** និងឯកសារថតចម្លងដូចជាអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ឬឯកសារផ្លូវការផ្សេងទៀតដែលបញ្ជាក់ពីអត្តសញ្ញាណរបស់អតិថិជន។

៣-ការពិពណ៌នាពីប្រភេទសេវាដែលផ្ដល់ជូនអតិថិជន និង/ឬសេវាកម្មផ្សេងទៀតដែលមានសម្រាប់អតិថិជន។

៤-ការពិពណ៌នាពីថ្លៃសេវា និងចំណាយផ្សេងៗដែលជាបន្ទុករបស់អតិថិជន។

៥-សេចក្ដីលម្អិតអំពីការផ្ដល់សិទ្ធិឱ្យភ្នាក់ងារក្នុងការរៀបចំការងារពាក់ព័ន្ធនឹងផលប្រយោជន៍ និងសិទ្ធិរបស់កម្មសិទ្ធិករមូលបត្រក្នុងនាមអតិថិជន។

៦-សេចក្ដីលម្អិតអំពីរបាយការណ៍ដែលអតិថិជនត្រូវទទួលបាន និងវិធីសាស្ត្រនៃការទទួលរបាយការណ៍ និងការជូនដំណឹងអំពីសេវារក្សាសុវត្ថិភាព។

៧-សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី។

៨-លក្ខខណ្ឌ និងនីតិវិធីនៃការផ្ដល់ ព្យួរ និងបញ្ឈប់សេវាដល់អតិថិជន។

៩-ការរក្សាការសម្ងាត់ និងការប្រើប្រាស់ព័ត៌មានសម្ងាត់របស់អតិថិជន។

១០-សេចក្ដីលម្អិតពីនីតិវិធីនៃការដោះស្រាយវិវាទ រួមទាំងការតវ៉ារបស់អតិថិជន។

១១-សេចក្ដីលម្អិតនៃការធានារ៉ាប់រងវិជ្ជាជីវៈរបស់ភ្នាក់ងារ។

១២-អ្នកទទួលសិទ្ធិបន្តក្នុងករណីអតិថិជនដែលចុះកិច្ចព្រមព្រៀងទទួលមរណភាព។

១៣-និទ្ទេសចាំបាច់ផ្សេងទៀតតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

ការបង្កើតគំរូកិច្ចព្រមព្រៀងអតិថិជនត្រូវទទួលបានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវចែងជាអប្បបរមានូវនិទ្ទេសដូចរៀបរាប់ខាងលើ និងមិនត្រូវកែប្រែ ឬលុបចោលនូវនិទ្ទេស ខ្លឹមសារណាមួយដែលទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** រួចឡើយ លើកលែងតែទទួលបានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.**។

## ជំពូកទី ៦
## កាតព្វកិច្ចរបស់ភ្នាក់ងារ

### ប្រការ ២៣.-កាតព្វកិច្ចទូទៅរបស់ភ្នាក់ងារ

ភ្នាក់ងារមានកាតព្វកិច្ចដូចខាងក្រោម÷

១-ត្រូវធានាការផ្ដល់សេវារក្សាសុវត្ថិភាពប្រកបដោយវិជ្ជាជីវៈ សុវត្ថិភាព និងប្រសិទ្ធភាព។

២-ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវរាល់លក្ខខណ្ឌតម្រូវសម្រាប់ការទទួលស្គាល់ភ្នាក់ងារ ដូចមានចែងក្នុងប្រការ ៦ ខាងលើ។

៣-ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍ស្ដីពីសេវារក្សាសុវត្ថិភាព កិច្ចព្រមព្រៀងអតិថិជន។

៤-ត្រូវបើក ត្រួតពិនិត្យ និងថែរក្សាគណនីរក្សាសុវត្ថិភាពរបស់អតិថិជន។

៥-ត្រូវថែរក្សាសុវត្ថិភាពសាច់ប្រាក់ មូលបត្រ និងទ្រព្យដទៃទៀតក្នុងនាមអតិថិជន។

៦-ត្រូវពិនិត្យ និងតាមដានប្រតិបត្តិការជួញដូរមូលបត្ររបស់អតិថិជនដែលបានអនុវត្ត។

៧-ត្រូវទូទាត់សាច់ប្រាក់ មូលបត្រ និងទ្រព្យដទៃទៀតក្នុងនាមអតិថិជន។

៨-ត្រូវសម្របសម្រួលប្តូររូបិយបណ្ណតាមការបញ្ជារបស់អតិថិជន។

៩-ត្រូវគណនា និងផ្ដល់របាយការណ៍ពាក់ព័ន្ធកាតព្វកិច្ចពន្ធជូនអតិថិជន និងបង់ប្រាក់ពន្ធក្នុងនាមអតិថិជន។

១០-ត្រូវគ្រប់គ្រង និងត្រួតពិនិត្យប្រតិបត្តិការសាច់ប្រាក់ មូលបត្រ និងទ្រព្យដទៃទៀតរបស់អតិថិជនសម្រាប់ការវិនិយោគពាក់ព័ន្ធនឹងមូលបត្រ។

១១-ត្រូវត្រួតពិនិត្យ និងគ្រប់គ្រងដោយប្រុងប្រយ័ត្នខ្ពស់នូវហានិភ័យនានាដែលអាចកើតមានឡើង។

១២-ត្រូវធ្វើការផ្ទៀងផ្ទាត់ និងផ្តល់របាយការណ៍នូវរាល់ប្រតិបត្តិការសាច់ប្រាក់ មូលបត្រ និងទ្រព្យដទៃទៀត ដែលទទួលបានពីបុគ្គលពាក់ព័ន្ធជូនអតិថិជនដើម្បីធានាថាប្រតិបត្តិការរបស់អតិថិជនត្រូវបានកត់ត្រាយ៉ាងត្រឹមត្រូវ និងមានបច្ចុប្បន្នភាព។

១៣-ត្រូវធ្វើការប្រមូល និងទូទាត់សាច់ប្រាក់ មូលបត្រ និងទ្រព្យដទៃទៀតទៅតាមកិច្ចព្រមព្រៀងអតិថិជន ហើយត្រូវជូនដំណឹងភ្លាមទៅអតិថិជន។

១៤-ត្រូវធ្វើការគណនាទ្រព្យសកម្មសុទ្ធ (Net Asset Value) និងធ្វើការកត់ត្រាទ្រព្យរបស់អតិថិជនតាមតម្លៃទីផ្សារ ព្រមទាំងរាយការណ៍ជូនអតិថិជន។

១៥-ត្រូវពិនិត្យគោលការណ៍ និងវិធីសាស្ត្រក្នុងការគណនាទ្រព្យសកម្មសុទ្ធរបស់បុគ្គលពាក់ព័ន្ធ ព្រមទាំងពិនិត្យការកំណត់តម្លៃទ្រព្យសកម្មសុទ្ធដើម្បីធានាថាការគណនានេះមានលក្ខណៈត្រឹមត្រូវ។

១៦-ត្រូវត្រួតពិនិត្យលើរាល់ការចំណាយ និងសកម្មភាពវិនិយោគពាក់ព័ន្ធនឹងមូលបត្រ ព្រមទាំងរាយការណ៍ជូនអគ្គនាយកនៃ **គ.ម.ក.** ក្នុងករណីពិនិត្យឃើញមានការអនុវត្តខុស ឬលាងសំអាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម ឬល្មើសនឹងគោលដៅនៃការវិនិយោគ។

## ប្រការ ២៤.-ការបណ្តុះបណ្តាល

អភិបាលទទួលបន្ទុក ប្រធានប្រតិបត្តិការ ប្រធានបុគ្គលិកជំនាញផ្នែកច្បាប់ និងប្រធានទទួលបន្ទុកផ្នែកហិរញ្ញវត្ថុរបស់ភ្នាក់ងារត្រូវចូលរួមវគ្គបណ្តុះបណ្តាលជាប្រចាំដែលរៀបចំដោយ **គ.ម.ក.**។

## ប្រការ ២៥.-ការការពារទ្រព្យក្នុងគណនីរក្សាសុវត្ថិភាព

ភ្នាក់ងារត្រូវបើកគណនីរក្សាសុវត្ថិភាពឱ្យអតិថិជនម្នាក់ៗក្រោមឈ្មោះអតិថិជន និងមិនត្រូវចាត់ទុកជាទ្រព្យរបស់ភ្នាក់ងារ ហើយត្រូវធានាថាទ្រព្យរបស់អតិថិជននៅក្នុងគណនីរក្សាសុវត្ថិភាពមិនត្រូវដាក់លាយឡំជាមួយទ្រព្យរបស់អតិថិជនដទៃទៀត ឬជាមួយទ្រព្យរបស់ភ្នាក់ងារឡើយ។

ភ្នាក់ងារមិនត្រូវចាត់ចែងសាច់ប្រាក់ មូលបត្រ និងទ្រព្យដទៃទៀតរបស់អតិថិជន ដែលមិនមានចែងក្នុងកិច្ចព្រមព្រៀងអតិថិជនឡើយ។

ទ្រព្យដែលរក្សាទុកនៅក្នុងគណនីរក្សាសុវត្ថិភាពមិនត្រូវយកទៅប្រើប្រាស់ដើម្បីទូទាត់បំណុលរបស់ភ្នាក់ងារ ឬបុគ្គលណាផ្សេង រាប់បញ្ចូលទាំងករណីមានបញ្ហាហិរញ្ញវត្ថុ ការគ្រប់គ្រងដោយអភិបាលបណ្តោះអាសន្ន ការជម្រះបញ្ជី ឬព្រឹត្តិការណ៍ស្រដៀងគ្នាផ្សេងទៀត។

## ប្រការ ២៦.-ការរក្សាការសម្ងាត់

ភ្នាក់ងារត្រូវរក្សាការសម្ងាត់ និងធានាថាអភិបាល ប្រធានប្រតិបត្តិការ ប្រធានបុគ្គលិកជំនាញផ្នែកច្បាប់ ប្រធានទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ ព្រមទាំងបុគ្គលិកដែលទទួលបន្ទុកការងារពាក់ព័ន្ធរបស់ភ្នាក់ងារត្រូវរក្សាការសម្ងាត់នូវរាល់ព័ត៌មានរបស់អតិថិជន និងមិនត្រូវផ្សព្វផ្សាយដល់តតិយជនឡើយ លើកលែងតែមានការតម្រូវដោយច្បាប់ សេចក្តីសម្រេចរបស់តុលាការ **គ.ម.ក.** ឬការព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់អតិថិជន។

## ប្រការ ២៧.-យន្តការសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃ

ភ្នាក់ងារត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវការត្រួតពិនិត្យផ្ទៃក្នុង និងការវាយតម្លៃលើដំណើរការនៃប្រតិបត្តិការនៃភ្នាក់ងារដើម្បីធានាប្រសិទ្ធភាពនៃដំណើរការផ្តល់សេវារក្សាសុវត្ថិភាព។

ការត្រួតពិនិត្យផ្ទៃក្នុងត្រូវមាននីតិវិធីដែលមានលក្ខណៈបង្ការ និងអង្កេត។ ការត្រួតពិនិត្យផ្ទៃក្នុងមានលក្ខណៈបង្ការមានគោលបំណងដើម្បីការពារ ឬកាត់បន្ថយឱ្យបានជាអតិបរមានូវការតែបន្លំ ឬកំហុស។ ការត្រួតពិនិត្យផ្ទៃក្នុងមានលក្ខណៈអង្កេតមានគោលបំណងដើម្បីស្វែងរកឱ្យឃើញនូវការតែបន្លំ ឬកំហុស ដើម្បីចាត់វិធានការកែតម្រូវឱ្យបានឆាប់រហ័ស។

ការត្រួតពិនិត្យផ្ទៃក្នុងត្រូវកត់ត្រាជាឯកសារ និងត្រូវកែសម្រួល ឬពិនិត្យឡើងវិញភ្លាមៗនៅពេលមានវិសោធនកម្មច្បាប់ ឬបទប្បញ្ញត្តិពាក់ព័ន្ធ។

**ប្រការ ២៨.-ការរក្សាកំណត់ត្រា និងឯកសារ**

ភ្នាក់ងារត្រូវរក្សាទុក និងការពារបញ្ជីគណនី និងឯកសារនានាដូចខាងក្រោមក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ÷

១-បញ្ជីឈ្មោះ និងអត្តសញ្ញាណរបស់អតិថិជន។

២-កំណត់ត្រាពាក់ព័ន្ធនឹងប្រតិបត្តិការសាច់ប្រាក់ មូលបត្រ និងទ្រព្យដទៃទៀតរបស់អតិថិជនរួមទាំងកំណត់ត្រានៃសេចក្តីលម្អិតពាក់ព័ន្ធនឹងការបញ្ជារបស់អតិថិជន។

៣-កំណត់ត្រាសកម្មភាពពាក់ព័ន្ធនឹងផលប្រយោជន៍ និងសិទ្ធិរបស់កម្មសិទ្ធិករមូលបត្ររបស់អតិថិជន។

៤-កិច្ចព្រមព្រៀងអតិថិជន ។

៥-បញ្ជីឈ្មោះបុគ្គលិកដែលទទួលខុសត្រូវប្រតិបត្តិការសេវារក្សាសុវត្ថិភាព។

៦-ការផ្លាស់ប្តូរបុគ្គលិកដែលទទួលខុសត្រូវប្រតិបត្តិការសេវារក្សាសុវត្ថិភាព។

៧-របាយការណ៍ដែលបានប្រគល់ជូន **គ.ម.ក.**។

៨-ឯកសារ ឬរបាយការណ៍ផ្សេងៗទៀតដែលតម្រូវដោយអគ្គនាយកនៃ **គ.ម.ក.**។

ភ្នាក់ងារត្រូវជូនដំណឹងដល់ **គ.ម.ក.** ពីទីកន្លែងរក្សាទុកសាច់ប្រាក់ មូលបត្រ និងទ្រព្យដទៃទៀតរបស់អតិថិជននីមួយៗ និងឯកសារដូចបានរៀបរាប់ក្នុងកថាខណ្ឌទី ១នៃប្រការនេះ។ កំណត់ត្រារបស់ភ្នាក់ងារដោយរួមបញ្ចូលទាំងទម្រង់អេឡិចត្រូនិចផង ត្រូវរក្សាទុកឱ្យបានត្រឹមត្រូវ និងត្រូវធានាថាឯកសារទាំងអស់មិនឱ្យបាត់បង់ ឬបំផ្លាញ ព្រមទាំងអាចទាញយកមកប្រើប្រាស់វិញបាន។

**ប្រការ ២៩.-របាយការណ៍ទាន់ពេល**

ភ្នាក់ងារត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ជូនអគ្គនាយកនៃ **គ.ម.ក.** នូវហេតុការណ៍ណាមួយដូចខាងក្រោម÷

១-ការកែប្រែនីតិវិធីប្រតិបត្តិការក្នុងការផ្តល់សេវានានា។

២-ការផ្លាស់ប្តូរអភិបាលទទួលបន្ទុក ប្រធានប្រតិបត្តិការ ប្រធានបុគ្គលិកជំនាញផ្នែកច្បាប់ ឬប្រធានទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ។

៣-ការផ្លាស់ប្តូរទីតាំងប្រកបអាជីវកម្ម។

៤-ការបញ្ឈប់ការផ្តល់សេវារក្សាសុវត្ថិភាពដល់អតិថិជន ឬផ្តល់សេវានេះជាថ្មីដល់អតិថិជននោះ។

៥-ការមិនអនុវត្តន៍តាមនីតិវិធីប្រតិបត្តិការ ឬកិច្ចព្រមព្រៀងអតិថិជន និងចំណាត់ការផ្សេងៗ។

៦-បញ្ហានានាដែលនាំឱ្យការផ្តល់សេវារក្សាសុវត្ថិភាពមិនបានសម្រេច។

៧-ការចាត់វិធានការនានា ដើម្បីជំនះលើស្ថានការណ៍លំបាក ឬហានិភ័យផ្សេងៗដែលប៉ះពាល់ដល់សេវារក្សាសុវត្ថិភាព។

៨-ព័ត៌មានផ្សេងទៀតតាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ៣០.-ការផ្តល់របាយការណ៍ប្រចាំខែ

ភ្នាក់ងារត្រូវផ្តល់ជូន **គ.ម.ក.** នូវរបាយការណ៍ប្រចាំខែ យ៉ាងយូរក្នុងរយៈពេល ៧ (ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការនៃខែបន្ទាប់ ឬក្នុងពេលវេលាណាមួយដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.**។

របាយការណ៍ប្រចាំខែនេះ ត្រូវបង្ហាញអំពីលទ្ធផលនៃប្រតិបត្តិការរបស់ភ្នាក់ងារ នូវព័ត៌មានដូចខាងក្រោម÷

១-ស្តីពីការបើក និងបិទគណនី

២-ស្តីពីប្រតិបត្តិការគណនីនីមួយៗ

៣-ស្តីពីសមតុល្យគណនីនីមួយៗ

៤-បញ្ជីឈ្មោះ និងអត្តសញ្ញាណរបស់អតិថិជន

៥-ប្រភេទទ្រព្យដែលរក្សាទុកនៅក្នុងគណនីរក្សាសុវត្ថិភាព

៦-បញ្ហាប្រឈមផ្សេងៗពាក់ព័ន្ធនឹងការផ្តល់សេវា

៧-ព័ត៌មានផ្សេងទៀតតាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ៣១.-ការផ្តល់របាយការណ៍ប្រចាំត្រីមាស

ភ្នាក់ងារត្រូវផ្តល់ជូន **គ.ម.ក.** នូវរបាយការណ៍ប្រចាំត្រីមាស យ៉ាងយូរក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីចុងត្រីមាសនីមួយៗ ឬក្នុងពេលវេលាណាមួយដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.**។

របាយការណ៍ប្រចាំត្រីមាសនេះ ត្រូវបង្ហាញអំពីលទ្ធផលនៃប្រតិបត្តិការរបស់ភ្នាក់ងារនូវព័ត៌មាន ដូចខាងក្រោម÷

១-ស្តីពីការបើក និងបិទគណនី

២-ស្តីពីប្រតិបត្តិការគណនីរបស់អតិថិជននីមួយៗ

៣-ស្តីពីសមតុល្យគណនីនីមួយៗ

៤-សកម្មភាពពាក់ព័ន្ធនឹងផលប្រយោជន៍ និងសិទ្ធិរបស់កម្មសិទ្ធិករមូលបត្រ

៥-ការចាត់ចែងទ្រព្យដែលរក្សាទុកក្នុងគណនីរក្សាសុវត្ថិភាព

៦-ផែនការសកម្មភាពប្រចាំត្រីមាស

៧-ព័ត៌មានផ្សេងទៀតតាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ៣២.-ការផ្តល់របាយការណ៍ប្រចាំឆ្នាំ

ក្នុងរយៈពេល ៣ (បី) ខែ បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធ ឬក្នុងពេលវេលាណាមួយដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.** ភ្នាក់ងារត្រូវផ្តល់ជូន **គ.ម.ក.** នូវរបាយការណ៍នៃឆ្នាំសារពើពន្ធកន្លងទៅដោយរាប់បញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ហើយរបាយការណ៍ប្រចាំឆ្នាំនេះ ត្រូវមានមាតិកាអប្បបរមាដូចខាងក្រោម÷

១-ព័ត៌មានទូទៅរបស់ភ្នាក់ងារ

២- សាររបស់អភិបាលទទួលបន្ទុក

៣- លទ្ធផលនៃប្រតិបត្តិការ

៤- ព័ត៌មានហិរញ្ញវត្ថុ

៥- ការពិភាក្សារបស់គណៈគ្រប់គ្រង

៦- ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម

៧- ព័ត៌មានស្តីពីសកម្មភាពពាក់ព័ន្ធនឹងផលប្រយោជន៍ និងសិទ្ធិរបស់កម្មសិទ្ធិករមូលបត្រ

៨- ព័ត៌មានអំពីផែនការអាជីវកម្ម

៩- ការចាត់វិធានការនានាដើម្បីជំនះលើស្ថានការណ៍លំបាក ឬហានិភ័យផ្សេងៗដែលប៉ះពាល់ដល់សេវារក្សាសុវត្ថិភាព

១០- ព័ត៌មានផ្សេងទៀតតាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ក.**។

ភ្នាក់ងារត្រូវផ្តល់ជូន **គ.ម.ក.** នូវរបាយការណ៍ទាន់ពេល ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំទៅតាមទម្រង់របាយការណ៍ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ៣៣.- ការតែងតាំង ឬផ្លាស់ប្តូរអភិបាលទទួលបន្ទុក ប្រធានប្រតិបត្តិការ ប្រធានបុគ្គលិកជំនាញផ្នែកច្បាប់ ឬប្រធានទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ

ភ្នាក់ងារត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជូនអគ្គនាយកនៃ **គ.ម.ក.** ក្នុងរយៈពេលមិនលើសពី ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ ចំពោះការបញ្ឈប់អភិបាលទទួលបន្ទុក ប្រធានប្រតិបត្តិការ ប្រធានបុគ្គលិកជំនាញផ្នែកច្បាប់ ឬប្រធានទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ ដោយបញ្ជាក់អំពីហេតុផលឱ្យបានច្បាស់លាស់។ ភ្នាក់ងារត្រូវជ្រើសរើសបេក្ខជនថ្មី ក្នុងរយៈពេលមិនលើសពី ៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ។

រាល់ការតែងតាំងឡើងវិញនូវអភិបាលទទួលបន្ទុក ប្រធានប្រតិបត្តិការ ប្រធានបុគ្គលិកជំនាញផ្នែកច្បាប់ ឬប្រធានទទួលបន្ទុកផ្នែកហិរញ្ញវត្ថុណាមួយរបស់ភ្នាក់ងារត្រូវទទួលបានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបំពេញពាក្យស្នើសុំតាមទម្រង់បែបបទ និងឯកសារភ្ជាប់ និងបង់ថ្លៃសេវាពាក្យស្នើសុំដូចមានចែងក្នុងប្រការ ២០ នៃប្រកាសនេះ។

## ប្រការ ៣៤.- ការផ្លាស់ប្តូរទីតាំងប្រកបអាជីវកម្ម ឬកែប្រែគោលការណ៍ស្តីពីសេវា ឬកែប្រែគំរូកិច្ចព្រមព្រៀងអតិថិជន

រាល់ការផ្លាស់ប្តូរទីតាំងប្រកបអាជីវកម្ម ឬកែប្រែគោលការណ៍ស្តីពីសេវារក្សាសុវត្ថិភាព ឬកែប្រែគំរូកិច្ចព្រមព្រៀងអតិថិជនរបស់ភ្នាក់ងារត្រូវទទួលបានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបំពេញពាក្យស្នើសុំតាមទម្រង់បែបបទ និងឯកសារភ្ជាប់ និងបង់ថ្លៃសេវាពាក្យស្នើសុំ ដូចមានចែងក្នុងប្រការ ២០ នៃប្រកាសនេះ។

## ប្រការ ៣៥.-ការផ្អាក និងការបញ្ឈប់អាជីវកម្ម

ភ្នាក់ងារត្រូវសុំ និងទទួលបានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.** ក្នុងករណីដូចខាងក្រោម÷

-ករណីផ្អាកសកម្មភាពផ្តល់សេវារក្សាសុវត្ថិភាព។

-ករណីបញ្ឈប់ការផ្តល់សេវារក្សាសុវត្ថិភាព។ ភ្នាក់ងារត្រូវដាក់ជូន **គ.ម.ក.** នូវសំណើសុំដោយបញ្ជាក់ពីហេតុផលឱ្យបានច្បាស់លាស់ និងភ្ជាប់មកជាមួយនូវនីតិវិធីនៃការបញ្ឈប់ការផ្តល់សេវា ហើយភ្នាក់ងារត្រូវបញ្ឈប់

ការផ្តល់សេវា និងធ្វើការទូទាត់ជាមួយអតិថិជនចាស់ឱ្យចប់សព្វគ្រប់ក្នុងរយៈពេលមិនលើសពី ៦ (ប្រាំមួយ) ខែ ឬរយៈពេលសមស្របណាមួយដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៣៦.-ការត្រួតពិនិត្យដោយ គ.ម.ក.**

ដំណើរការអាជីវកម្ម និងប្រសិទ្ធភាពនៃប្រតិបត្តិការអាជីវកម្មរបស់ភ្នាក់ងារត្រូវបានត្រួតពិនិត្យដោយមន្ត្រីរបស់ **គ.ម.ក.**។

ភ្នាក់ងារត្រូវផ្តល់កិច្ចសហការដល់មន្ត្រីរបស់ **គ.ម.ក.** ក្នុងគោលបំណងធានានូវប្រសិទ្ធភាពការងារ។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**ប្រការ ៣៧.-វិធានការរដ្ឋបាល**

ភ្នាក់ងារ ព្រមទាំងបុគ្គលពាក់ព័ន្ធដែលល្មើសនឹងប្រការ ២១ ប្រការ ២២ ប្រការ ២៣ ប្រការ ២៤ ប្រការ ២៥ ប្រការ ២៦ ប្រការ ២៧ ប្រការ ២៨ ប្រការ ២៩ ប្រការ ៣០ ប្រការ ៣១ ប្រការ ៣២ ប្រការ ៣៣ ប្រការ ៣៤ ប្រការ ៣៥ កថាខណ្ឌទី២ នៃប្រការ ៣៦ នៃប្រកាសនេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលពី **គ.ម.ក.**។

អគ្គនាយកនៃ **គ.ម.ក.** អាចដាក់ទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម÷

១-ព្រមាន

២-ដឹកនាំកែតម្រង់

៣-ដាក់កំហិតលើការទទួលស្គាល់

៤-ព្យួរការទទួលស្គាល់

៥-ដកហូតការទទួលស្គាល់

**ប្រការ ៣៨.-វិធានការពិន័យអន្តរការណ៍**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិនៅក្នុងវិស័យមូលបត្រ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ភ្នាក់ងារ និងបុគ្គលពាក់ព័ន្ធ ដែលប្រព្រឹត្តល្មើសនឹងប្រការ ២០ ចំណុច ៤ ៧ ៩ ១០ ១១ ១២ ១៣ ១៤ ១៥ នៃប្រការ ២៣ ប្រការ ២៥ កថាខណ្ឌទី២ នៃប្រការ ៣៦ ព្រមទាំងប្រការ ៣៧ នៃប្រកាសនេះ ឬមិនគោរពតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.** ត្រូវទទួលទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី ២ នៃប្រការ ៣៧ នៃប្រកាសនេះ និង/ឬទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់÷

១-មិនលើសពី ១០០.០០០.០០០ (មួយរយលាន) រៀល ចំពោះរូបវន្តបុគ្គល។

២-មិនលើសពី ២០០.០០០.០០០ (ពីររយលាន) រៀល ចំពោះនីតិបុគ្គល។

ករណីភ្នាក់ងារដែលប្រព្រឹត្តល្មើសនឹងប្រការ ១៩ នៃប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ចំពោះការបង់ថ្លៃសេវាប្រចាំឆ្នាំយឺតយ៉ាវនេះ ក្នុង ១ (មួយ) ថ្ងៃជាសាច់ប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**ប្រការ ៣៩.-គោលការណ៍ណែនាំផ្សេងៗ**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាស នេះដល់បុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងដល់សាធារណជន។

**ប្រការ ៤០.-បដិវាទកម្ម**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤១.-ការអនុវត្ត**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ១៥កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ ៤១ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ